UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា
The Special Representative of the Secretary-General
for human rights in Cambodia

COHCHR

## កំណត់សំគាល់សង្ខេប

### កាតព្វកិច្ចរបស់ប្រទេសកម្ពុជា នៅក្រោមអនុសញ្ញាអន្តរជាតិ
### ស្តីពីឋានៈនៃជនភៀសខ្លួន និង នៅក្រោមច្បាប់អន្តរជាតិ

ប្រទេសកម្ពុជាគឺជាភាគីមួយនៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៥១ ស្តីឋានៈនៃជនភៀសខ្លួន និងពិធីសារពាក់ព័ន្ធឆ្នាំ ១៩៦៧។ ដូច្នេះ ប្រទេសកម្ពុជាបានទទួលខុសត្រូវថានឹងមិនធ្វើការបញ្ជូនអ្នកស្វែងរកសិទ្ធិជ្រកកោន ឬជនភៀសខ្លួនដោយបង្ខំឱ្យត្រឡប់ "រុញច្រានឱ្យថយក្រោយ" វិញ ទៅឯព្រំដែននៃទឹកដីដែលជីវិត ឬសេរីភាពរបស់គេមានការគំរាមកំហែង ដោយសំអាងលើជាតិសាសន៍ សាសនា សញ្ជាតិ សមាជិកភាពរបស់ក្រុមសង្គមមួយ ឬគំនិតនយោបាយដោយឡែករបស់គេ (មាត្រា៣៣) ។ ប្រទេសកម្ពុជាក៏ត្រូវទទួលខុសត្រូវផងដែរ ដោយមិនត្រូវដាក់ទណ្ឌកម្មទៅលើអ្នកស្វែងរកសិទ្ធិជ្រកកោន ដែលចូលក្នុងទឹកដីនៃប្រទេសកម្ពុជាដោយខុសច្បាប់ (មាត្រា៣១) ។

ផ្នែកសំខាន់នៃកា តព្វកិច្ចនោះគឺការមិនបញ្ជូនឱ្យត្រឡប់ទៅវិញនោះគឺ :

១- ការមិនបញ្ជូនត្រឡប់ទៅ ឯព្រំដែនវិញ និង
២- សេចក្តីត្រូវការឱ្យមាននីតិវិធីក្នុងការកំណត់ឋានៈនៃជនភៀសខ្លួនឱ្យបានត្រឹមត្រូវថាតើជនណាខ្លះដែលត្រូវផ្តល់ការការពារ។

អ្នកស្វែងរកសិទ្ធិជ្រកកោនអាចត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ផ្អែកលើលក្ខណ្ឌពីរគឺ : ទី១ គឺ ពាក្យសុំទទួលស្គាល់ឋានៈជាជនភៀសខ្លួនត្រូវបានបដិសេធ បន្ទាប់ពីឆ្លងកាត់ការពិនិត្យ តាមរយៈនីតិវិធីក្នុងការកំណត់ឋានៈជនភៀសខ្លួនយ៉ាងត្រឹមត្រូវ។ ទី២ គឺ មិនមានហេតុដែលអាចជឿបានថា ប្រសិនបើបញ្ជូនត្រឡប់ទៅវិញ អាយុជីវិត ឬសេរីភាពរបស់ពួកគេនឹងមានការគំរាមកំហែង ដោយសារបញ្ហាជាតិសាសន៍ សាសនា សញ្ជាតិ សមាជិកភាពរបស់ក្រុមសង្គម ឬគំនិតនយោបាយដោយឡែកណាមួយរបស់គេ (មាត្រា៣៣) ឬមួយក៏ត្រូវទទួលរងនូវទារុណកម្ម[១] ។

ប្រទេសកម្ពុជាមិនបានបង្កើតនៅឡើយនូវនីតិវិធីសំរាប់ការចុះឈ្មោះ និងការទទួលអ្នកស្វែងសិទ្ធិជ្រកកោន ដើម្បីធ្វើនិយ័តកម្មអំពីឋានៈតាមផ្លូវច្បាប់នៃអ្នកស្វែងរកសិទ្ធិជ្រកកោន ដែលចូលមកក្នុងប្រទេសដោយខុសច្បាប់ ឬដើម្បីកំណត់សំរេចអំពីឋានៈជាជនភៀសខ្លួន។ តាំងពីមុនរហូតមកទល់ពេលនេះ គឺការិយាល័យឧត្តមស្នងការអ.ស.បទទួលបន្ទុកជនភៀសខ្លួន (UNHCR) បានទទួលរ៉ាប់រងអនុវត្តភារកិច្ចនេះ។ រហូតដល់រដ្ឋាភិបាលនិងការិយាល័យរបស់អង្គការUNHCR ចុះកិច្ចព្រមព្រៀងមួយស្តីពីប្រព័ន្ធសមស្របរបស់ប្រទេសកម្ពុជាសំរាប់កំណត់សំរេចអំពីឋានៈជនភៀសខ្លួន និងរហូតដល់ការិយាល័យរបស់អង្គការUNHCR អាចបំពេញការងាររបស់ខ្លួននៅ

[១] មាត្រា ៣ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការដាក់ទោស និងការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់កិត្តិយស ជាមនុស្ស

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cohchr@online.com.kh Internet: www.unhchr.ch/cambodia

នៅក្នុងប្រទេសកម្ពុជាបានដោយគ្មានការរិតត្បិតនោះ អ្នកស្វែងរកសិទ្ធិជ្រកកោនអាចធ្វើដំណើរទៅដាក់ពាក្យសុំរបស់ខ្លួននៅឯការិយាល័យរបស់អង្គការUNHCR បានដោយសេរី ដើម្បីឱ្យប្រទេសកម្ពុជាអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្រោមសន្ធិសញ្ញាអន្តរជាតិ ។

ប្រការដែលអ្នកស្វែងរកសិទ្ធិជ្រកកោនពីប្រទេសវៀតណាម មិនបង្ហាញខ្លួនចំពោះអាជ្ញាធររបស់កម្ពុជានោះ ក៏ដោយសារភ័យខ្លាចការបង្ខិតបង្ខំឱ្យត្រឡប់ទៅវិញ និងការខ្លាចការដាក់ទណ្ឌកម្ម ព្រោះបានចូលដោយខុសច្បាប់ ។ ពួកគេបានព្យាយាមយ៉ាងណារកផ្លូវអោយបានទៅដល់ការិយាល័យរបស់អង្គការUNHCRនៅក្នុងរាជធានីភ្នំពេញ ដែលជាមធ្យោបាយតែមួយគត់ ដើម្បីឱ្យបានសំរេចលើការ ទាមទារឋានៈជាជនភៀសរបស់ពួកគេ និងដើម្បីធ្វើនិយ័តកម្មឋានៈតាមផ្លូវច្បាប់របស់ពួកគេ ។

អ្នកណាក៏ដោយដែលជួយដល់អ្នកស្វែងរកសិទ្ធិជ្រកកោន ដែលរួមមានទាំងឯកត្តបុគ្គល និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការដើម្បីការពារសិទ្ធិមនុស្ស និងផ្តល់ជំនួយមនុស្សធម៌ មិនគួរចាត់ទុកថាជាអំពើខុសច្បាប់ និងមិនត្រូវទទួលរងនូវការយាយី ការគំរាមកំហែង ឬការសងសឹកផ្សេងទៀតទេ ។ ពួកគេគ្រាន់តែជួយដល់អ្នកដែលស្វែងសិទ្ធិជ្រកកោន ដើម្បីអនុវត្តនូវសិទ្ធិរបស់គេក្រោមច្បាប់អន្តរជាតិ ដែលប្រទេសកម្ពុជាត្រូវជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការអនុវត្តតាមដែរតែប៉ុណ្ណោះ ។ ក្នុងការជួយដល់អ្នកស្វែងរកសិទ្ធិជ្រកកោន គឺឯកត្តបុគ្គល និងអង្គការក្រៅរដ្ឋាភិបាលនានាគ្រាន់តែអនុវត្តសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន ក្នុងការលើកស្ទួយសិទ្ធិមនុស្ស និងជួយក្នុងការការពារពួកគេ ស្របតាមសេចក្តីប្រកាសរបស់អ.ស.ប ស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គមក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសាកល និងគ្រាន់តែជួយក្នុងការផ្តល់ជំនួយមនុស្សធម៌ ដើម្បីសំរាលដល់ទុក្ខវេទនា ដោយមិនគិតពីមូលហេតុ ហើយនិងផ្តល់ការពារពួកគេឱ្យរួចផុតពីការគំរាមកំហែងដល់អាយុជីវិតតែប៉ុណ្ណោះ ។

អាជ្ញាធរទាំងឡាយមានភារកិច្ចជាទូទៅមួយ គឺត្រូវតែគោរពសិទ្ធិរបស់បុគ្គលគ្រប់រូបទាំងអស់នៅក្នុងទឹកដីរបស់ខ្លួន ដោយមិនគិតពីបញ្ហាសញ្ជាតិឡើយ ដែលសិទ្ធិទាំងនោះត្រូវបានការពារដោយសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាបានចូលជាភាគី ។ ផ្អែកតាមអនុសញ្ញាអន្តរជាតិស្តីពីជនភៀសខ្លួន ជនទាំងឡាយដែលត្រូវបានទទួលស្គាល់ថាជាជនភៀសខ្លួន ត្រូវមានសិទ្ធិទទួលនូវសិទ្ធិមនុស្សមួយចំនួន រួមមានសិទ្ធិខាងសេដ្ឋកិច្ច និងសង្គមកិច្ចដូចជា សិទ្ធិក្នុងការទទួលការថែទាំផ្នែកវិជ្ជសាស្ត្រ ការសិក្សារៀនសូត្រនៅក្នុងប្រទេសដែលខ្លួនជ្រកកោន ។

ការផ្តល់សិទ្ធិជ្រកកោនដល់ជនភៀសខ្លួនមិនគួរចាត់ទុកជាអំពើអរិយភាពឡើយ ។ រដ្ឋជាភាគីនៃអនុសញ្ញាស្តីពីឋានៈនៃជនភៀសខ្លួន នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ មានចំនួនជាង១៤០ ប្រទេសបានផ្តល់សិទ្ធិជ្រកកោនដល់ជនភៀសខ្លួន ដែលមកពីប្រទេសនានាដែលពួកគេមានទំនាក់ទំនងមិត្តភាពខាងការទូត ។ ប្រទេសភាគច្រើនបានបង្កើតឱ្យមានប្រព័ន្ធថ្នាក់ជាតិសំរាប់កំណត់សំរេចពីឋានៈនៃជនភៀសខ្លួន ផ្អែកលើករណីនីមួយៗ ថាតើអ្នកស្វែងរកសិទ្ធិជ្រកកោនស្ថិតនៅក្នុងវិសាលភាពនៃអនុសញ្ញានេះ ហើយដែលត្រូវទទួលបានការការពារដែរឬទេ ។ តាមធម្មតាការកំណត់សំរេចពីឋានៈនេះ ត្រូវបានធ្វើឡើងដោយអ្នកធ្វើសេចក្តីសំរេចដែលឯករាជ្យ និងមិនលំអៀង ដែលអនុវត្តច្បាប់មិនគិតពីនិន្នាការនយោបាយ ។

១៦ កក្កដា ២០០៤

**មាត្រា ៣១ ៖ ជនភៀសខ្លួននៅមិនស្របច្បាប់ក្នុងប្រទេសដែលខ្លួនជ្រកកោន**

១. រដ្ឋភាគីនៃអនុសញ្ញា មិនត្រូវបង្ខំដាក់ទណ្ឌកម្ម ដោយសារការចូល ឬមានវត្តមានខុសច្បាប់ ទៅលើជនភៀសខ្លួនដែលចូលមកដោយត្រង់ពីទឹកដីដែលជីវិត និងសេរីភាពរបស់គេទទួលរងការគំរាមគំហែង ដូចមានចែងក្នុងមាត្រា១ ដែលចូល ឬមានវត្តមានលើទឹកដីនៃរដ្ឋភាគីដោយពុំមានការអនុញ្ញាត បើពួកគេបានបង្ហាញខ្លួនភ្លាមៗ នៅចំពោះមុខអាជ្ញាធរ និងបានបង្ហាញពីមូលហេតុត្រឹមត្រូវចំពោះការចូល ឬ ការមានវត្តដោយខុសច្បាប់របស់ខ្លួន។

២. រដ្ឋភាគីនៃអនុសញ្ញា មិនត្រូវដាក់ការរិតត្បិតលើសិទ្ធិដើរហើរចំពោះជនភៀសខ្លួនបែបនោះឡើយ លើកលែងតែការរិតត្បិតនោះចាំបាច់ ហើយការរិតត្បិតបែបនោះ អាចយកមកអនុវត្តបានទាល់តែឋានៈរបស់ពួកគេនៅក្នុងប្រទេសនោះ ត្រូវបានធ្វើត្រឹមត្រូវស្របតាមច្បាប់ ឬពួកគេទទួលបានការអនុញ្ញាតឱ្យចូលទៅក្នុងប្រទេសមួយទៀត។ រដ្ឋភាគីនៃអនុសញ្ញា ត្រូវអនុញ្ញាតឱ្យជនភៀសខ្លួនបែបនោះនូវរយៈពេលសមស្រប និងសម្ភារៈរូបវ័ន្តចាំបាច់ ដើម្បីទទួលបានការអនុញ្ញាតឱ្យចូលទៅក្នុងប្រទេសមួយផ្សេងទៀត។

**មាត្រា ៣៣៖ ហាមឃាត់ការបណ្ដេញចេញ ឬបញ្ជូនត្រឡប់ "បញ្ជូនចេញដោយបង្ខំ"**

១. គ្មានរដ្ឋភាគីនៃអនុសញ្ញាណាមួយ ត្រូវបណ្ដេញចេញ ឬបញ្ជូនត្រឡប់វិញនូវជនភៀសខ្លួនណាម្នាក់ ទោះតាមលក្ខណៈបែបណាក៏ដោយ ឱ្យទៅកាន់ព្រំដែននៃទឹកដី ជាកន្លែងដែលជីវិតនិង សេរីភាពរបស់ពួកគេមុខជានឹងទទួលរងការគំរាមកំហែង ដោយសារបញ្ហាជាតិសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមណាមួយនៃសង្គម ឬមតិនយោបាយ។

២. ទោះជាយ៉ាងណាក៏ដោយ ផលប្រយោជន៍នៃបទបញ្ញត្តិនេះ មិនអាចយកមកសំអាងដោយជនភៀសខ្លួនណាម្នាក់ ដែលមានមូលដ្ឋានសមស្របថា ជននោះអាចជាគ្រោះថ្នាក់ដល់សន្តិសុខរបស់ប្រទេសដែលជននោះត្រូវបានតុលាការចេញសាលក្រមស្ថាពរកាត់ឱ្យជាប់ទោសពីបទឧក្រិដ្ឋជាក់ស្ដែងធ្ងន់ធ្ងរ ឬជននោះជាគ្រោះថ្នាក់ដល់សហគមន៍នៃប្រទេសនោះ។